**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-May-2016, 10:55
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ ជាមួយឧបសម្ពន្ធសាធារណៈ៣

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**សារណារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងឯកសារគម្រោងជើងឯក**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

**មេធាវីប្រចាំការ:**
លោកស្រី ទូច វរល័ក្ស
លោក Calvin SAUNDERS

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង និងជាការឆ្លើយតបទៅនឹង "ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និងការក្រើនរម្លឹកទាក់ទងនឹងសំណើនានា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត"[1]("សេចក្តីជូនដំណឹង") សហព្រះរាជអាជ្ញាសូមដាក់ជូនសំណើនេះសុំឱ្យទទួលយកជាភស្តុតាងនូវ "ការវាយតម្លៃការអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាតជើងឯក"[2]("ការវាយតម្លៃ") និងការសិក្សាស្តីពីអដ្ឋិធាតុនៅជើងឯកចំនួន៣៥ទំព័រ ដូចបានកំណត់អត្តសញ្ញាណនៅក្នុងឯកសារ E404 ("ការសិក្សាស្តីពីជើងឯក")។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គេមិនចាំបាច់ដែលតម្រូវឱ្យផ្នែកដែលនៅសេសសល់នៃការសិក្សាស្តីពីអដ្ឋិធាតុនៅជើងឯក ត្រូវបានទទួលយកនៅពេលនេះទេ។

## II. ប្រវត្តិនីតិវិធី

2. នៅព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ មេធាវីការពារក្តី នួន ជា បានផ្ញើសារអេឡិចត្រូនិកមួយជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនៃសំណុំរឿង០០២ ដោយជូនដំណឹងថាពួកគេមានចេតនាចង់ធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់នាថ្ងៃនោះ ពាក់ព័ន្ធនឹងការទទួលយកជាភស្តុតាងនូវអត្ថបទមួយដែលបានផ្សព្វផ្សាយកាសែតក្នុងស្រុកសរសេរជាភាសាអង់គ្លេស គឺភ្នំពេញប៉ុស្តិ៍[3]។ អត្ថបទដែលមានចំណងជើងថា "ពីលលាដ៍ក្បាលមួយទៅលលាដ៍ក្បាលមួយទៀត ក្រុមកំពុងតែធ្វើកាតាឡុកនៃការសម្លាប់របស់ខ្មែរក្រហម"[4] ("អត្ថបទ") ដែលបានរៀបរាប់អំពីការស៊ើបអង្កេតមានរយៈពេលពីរឆ្នាំ ដែលបានដឹកនាំធ្វើនៅជើងឯក ដោយបុរាណវិទូ និងក្រុមអ្នកស៊ើបអង្កេតមួយក្រុម "ស្វែងរកទិន្នន័យ

---

[1] E404 ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និងការក្រើនរម្លឹកទាក់ទងនឹងសំណើនានា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត, ២ ឧសភា ២០១៦ (ចាប់ពីនេះតទៅហៅថា "សេចក្តីជូនដំណឹង")។

[2] វាយតម្លៃការអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ក្នុងគម្រោងសិក្សាអំពីការសម្លាប់ នៅលើឃ្លាំងផ្ទុកឯកសាររួម (SMD) ត្រង់ ENG ERN 01235378-01235427, KH 01235428-01235506 (ចាប់ពីនេះតទៅហៅថា "ការវាយតម្លៃ")។

[3] សារអេឡិចត្រូនិក ពីមេធាវីការពារក្តី នួន ជា មានចំណងជើងថា "សេចក្តីសន្និដ្ឋានផ្ទាល់មាត់ថ្ងៃនេះ ពាក់ព័ន្ធនឹងការទទួលយកនិងការប្រើប្រាស់ឯកសារមួយ", ២១ មេសា ២០១៦, ម៉ោង ៨:៥១ព្រឹក (ភ្ជាប់ជាប្រភពឯកសារយោង១។)

[4] Crane, Brent, "ពីលលាដ៍ក្បាលមួយទៅលលាដ៍ក្បាលមួយទៀត ក្រុមកំពុងតែធ្វើកាតាឡុកនៃការសម្លាប់របស់ខ្មែរក្រហម", ភ្នំពេញប៉ុស្តិ៍, ៦ កុម្ភៈ ២០១៦, អាចរកបានតាមវិបសាយ http://www.phnompenhpost.com/post-weekend/skull-skull-team-catalogues-kr-killings (ថ្ងៃចូលមើលចុងក្រោយ ៥ ឧសភា ២០១៦)។

ដែលពួកគេអាចប្រើសម្រាប់ទាញសេចក្តីសន្និដ្ឋានអំពីអាយុ ភេទ និងរបៀបនៃការស្លាប់របស់ជនរងគ្រោះ"[5]។ អត្ថបទនេះបាននិយាយបន្ថែមថា ការស៊ើបអង្កេត "បានពិនិត្យលលាដ៍ក្បាលចំនួន ៦,៤២៦" និង "បានកំណត់អត្តសញ្ញាណវិធីសាស្ត្រចំនួន១៧ ដែលគេបានប្រើដើម្បីសម្លាប់នៅជើងឯក រួមទាំងប្រភេទខុសៗគ្នានៃការប៉ះទង្គិចធ្ងន់ធ្ងរដោយឧបករណ៍ទាល (blunt force trauma) ទៅលើក្បាល និងកញ្ចឹងកជនរងគ្រោះ ព្រមទាំងការប្រើកាំបិទចែតកាប់ក្បាល និងអារផ្តាច់បំពង់ក។ អត្ថបទក៏មានការរៀបរាប់អំពីកំណាតហេតុនានាដែលសាក្សីនៅក្នុងសំណុំរឿង០០២ ហ៊ឹម ហ៊ុយ បានធ្វើជូនក្រុមអ្នកស៊ើបអង្កេតទាក់ទងនឹងប្រតិបត្តិការនៅជើងឯកផងដែរ។ ឯកសារក្នុងទម្រង់ជា PDF និងការភ្ជាប់ទៅនឹងអត្ថបទនេះ ដែលអាចរកបាននៅលើវិបសាយ ត្រូវបានដាក់បញ្ចូលនៅក្នុងសារអេឡិចត្រូនិក[6]។

3. នៅក្នុងសាលសវនាការនាពេលព្រឹកថ្ងៃដដែលនោះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យភាគីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ទាក់ទងនឹងការទទួលយកអត្ថបទនេះ[7]។ នួន ជា បានធ្វើការសន្និដ្ឋានថា អត្ថបទនេះរៀបរាប់នូវ "អ្វីដែលហាក់ដូចជាកិច្ចស៊ើបសួរកោសល្យវិច័យយ៉ាងទូលំទូលាយ... ដែលបានកើតឡើងនៅជើងឯក" និងគាំទ្រចំពោះការទទួលយកអត្ថបទដែលរៀបរាប់អំពីគុណវុឌ្ឍិរបស់ប្រធានក្រុមស៊ើបអង្កេត ព្រមទាំងរបកគំហើញខ្លះដែលបានឆ្លុះបញ្ចាំងនៅក្នុងអត្ថបទនោះ[8]។ នួន ជា បានថ្លែងបន្ថែមថា៖ "យើងជឿថា - តាមពិត កិច្ចស៊ើបសួរកោសល្យវិច័យពេញលេញ នឹងបានជាចំណាប់អារម្មណ៍យ៉ាងខ្លាំង... មិនមែនត្រឹមតែសម្រាប់អង្គជំនុំជម្រះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់គ្រប់ភាគីទាំងអស់ផងដែរ"[9]។ គាត់ក៏បាននិយាយផងដែរថា គាត់បានទាក់ទងប្រធានក្រុមស៊ើបអង្កេតដូចបានកំណត់អត្តសញ្ញាណក្នុងអត្ថបទនោះហើយ គឺ លោក វឿន វុទ្ធី ដើម្បីឱ្យដឹងថាតើ គាត់អាចសុំរបាយការណ៍កោសល្យវិច័យមួយច្បាប់ដែលបានផលិតឡើងតាមការស្រាវជ្រាវនៅជើងឯកនេះដែរឬទេ និងបានថ្លែងថា "យើងជឿថាអត្ថបទនេះ ប៉ុន្តែបន្តបន្ទាប់មកទៀត ជា

---

5 Crane, Brent, "ពីលលាដ៍ក្បាលមួយទៅលលាដ៍ក្បាលមួយទៀត ក្រុមកំពុងតែធ្វើកាតាឡុកនៃការសម្លាប់របស់ខ្មែរក្រហម", ភ្នំពេញប៉ុស្តិ៍, ៦ កុម្ភៈ ២០១៦, អាចរកបានតាមវិបសាយ http://www.phnompenhpost. com/post-weekend/skull-skull-team-catalogues-kr-killings (ថ្ងៃចូលមើលចុងក្រោយ ៥ ឧសភា ២០១៦)។

6 អត្ថបទនេះដូចជាមិនទាន់បានដាក់នៅក្នុង Zylab ទេ។

7 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.33.38។

8 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.34.55-11.35.46។

9 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.35.46។

របាយការណ៍កោសល្យវិច័យ ដែលអត្ថបទនេះលើកយោង គឺជាការរួមចំណែកនៅក្នុងការស្វែងរកការពិត"[10]។

4. នៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន សហព្រះរាជអាជ្ញាបានយល់ស្របថា អត្ថបទនេះ "ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងកិច្ចដំណើរការនីតិវិធីទាំងនេះ"[11] ហើយក៏មិនជំទាស់ក្នុងការដាក់អត្ថបទនេះជាភ័ស្តុតាងឡើយ[12]។ សហព្រះរាជអាជ្ញាក៏បានយល់ស្របជាមួយ នួន ជា ថា យើងគួរទទួលបានរបាយការណ៍ពេញលេញ និងដាក់បញ្ចូលជាភ័ស្តុតាង[13]។ ជាការឆ្លើយតប នួន ជា បាននិយាយថាពួកគេ "សប្បាយចិត្តណាស់ដែលបានឮថា តំណាងអយ្យការជាអ្នករកឃើញអត្ថបទនេះ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺរបាយការណ៍ជាមូលដ្ឋាននេះមានការពាក់ព័ន្ធយ៉ាងខ្លាំង"[14]។

5. នៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបានថ្លែងថា ពួកគេគ្មានការជំទាស់ក្នុងការទទួលយករបាយការណ៍នេះទេ[15]។ ចំណែកនៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ ខៀវ សំផន វិញ គាត់បានថ្លែងថាគាត់មិនជំទាស់ទៅនឹងការស្នើសុំរបស់ នួន ជា ទេ[16]។

6. នៅរសៀលថ្ងៃដដែល អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអត្ថបទនោះ អនុលោមតាមវិធាន ៨៧(៤)[17]។ អង្គជំនុំជម្រះសាលាដំបូងធ្វើការកត់សម្គាល់ទៅលើសំណើរបស់ នួន ជា និងសហព្រះរាជអាជ្ញា ដែលសុំឱ្យទទួលយករបាយការណ៍ជាមូលដ្ឋាននេះ ព្រមទាំងបានយល់ព្រមតាមសំណើ និងបានថ្លែងថា អង្គជំនុំជម្រះនឹងជូនដំណឹងដល់គូភាគីអំពីកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីទទួលបានរបាយការណ៍នេះ។ អង្គជំនុំជម្រះក៏បានពន្យារសេចក្តីសម្រេចរបស់ខ្លួន ក្នុងការទទួលយករបាយការណ៍នេះ ដោយរង់ចាំរហូតដល់អង្គជំនុំជម្រះទទួលបានរបាយការណ៍ជាមុនសិន[18]។

---

10 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.35.46។

11 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.38.16។

12 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.39.37។

13 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.39.37។

14 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.40.43។

15 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.41.41។

16 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.42.25។

17 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 11.42.25។

18 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, 13.36.44។

7. នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីជូនដំណឹងមួយ[19]។ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងក្នុងលិខិតនោះថាខ្លួនបានទាក់ទងលោក វឿន វុទ្ធី, ជូលី ហ្វ្លេសម៉ែន(Julie Fleischman) (ជានិស្សិតបណ្ឌិតខាងរូប-នរវិទ្យា ដែលបានចូលរួមចំណែកនៅក្នុងការសិក្សា ហើយដែលត្រូវបានកំណត់អត្តសញ្ញាណផងដែរនៅក្នុងអត្ថបទ) និង រស់ សុភាវ៉ារី ដែលជាអនុប្រធាននៃមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ហើយបានរកឃើញភាពពាក់ ពន្ធ័ជាមួយនឹងការដាក់ជូនទាំងនេះដូចតទៅ៖១) ការសិក្សាអំពីជើងឯកចំនួន ១១ភាគ ក្នុងចំណោម ៣២ភាគ អាចរកបាន នៅក្នុងបណ្ណាល័យ អវតក ជាភាសាខ្មែរ ចាប់តាំងពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥។ ២) ភាគដែលនៅសេសសល់ឥឡូវនេះ គេអាចរកបាននៅក្នុងបណ្ណាល័យ អវតក ជាភាសាខ្មែរ។ ៣) ការសិក្សានៅជើងឯក មិនមែនជា "របាយការណ៍កោសល្យវិច័យទេ" ប៉ុន្តែជា "ការសិក្សាអំពី អដ្ឋិវិទ្យា (ឆ្អឹង) ដោយមានការសង្កត់ធ្ងន់ទៅលើអដ្ឋិសង្ខលិកដែលរងរបួស"។ និង ៤) "របាយការណ៍ស្តីពីការវាយតម្លៃពីក្រៅកម្មវិធី" នៃការសិក្សានៅជើងឯក ជាភាសាអង់គ្លេស និងជាភាសាខ្មែរ ដែលសង្ខេបពីរបកគំហើញនៃការសិក្សានៅជើងឯក, អាចរកបាននៅបណ្ណាល័យ អវតក ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៦ និងឥឡូវនេះ ត្រូវបានដាក់ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម[20]។

8. នៅក្នុងសេចក្តីជូនដំណឹង អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យមានសារណាជាលាយលក្ខណ៍អក្សរ មិនលើសពី១០ទំព័រ ពីគូភាគី អំពីថាតើការសិក្សាស្តីពីជើងឯក និង/ឬការវាយតម្លៃ គួរទទួលយកជាភ័ស្តុតាងដែរឬអត់[21]។ ភាគីត្រូវបានផ្តល់នូវពេលវេលារហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ដើម្បីដាក់សារណា[22]។

---

19 **E404** សេចក្តីជូនដំណឹង។

20 **E404** សេចក្តីជូនដំណឹង, ត្រង់ កថាខណ្ឌ២-៤។

21 **E404** សេចក្តីជូនដំណឹង, ត្រង់ កថាខណ្ឌ៥។

22 អង្គជំនុំជម្រះសាលាដំបូង ពីដំបូងផ្តល់កាលបរិច្ឆេទកំណត់ចុងក្រោយ ត្រូវនឹងថ្ងៃទី៦ ខែឧសភា ២០១៦។ **E404** សេចក្តីជូនដំណឹង, ត្រង់ កថាខណ្ឌ៥។ កាលបរិច្ឆេទកំណត់ចុងក្រោយនោះ ត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ តាមរយៈសារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង។ សារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង, ៣ ឧសភា ២០១៦, ម៉ោង ៣:៤២រសៀល (ភ្ជាប់ជាប្រភពឯកសារយោង២)។

## III. សេចក្តីនិដ្ឋាន

9. ថ្មីៗនេះ អង្គជំនុំជម្រះនេះបានបញ្ជាក់ឡើងវិញអំពីច្បាប់ដែលអាចអនុវត្តបានទាក់ទងនឹងការទទួលយកភស្តុតាងថ្មី៖

> អង្គជំនុំជម្រះរម្លឹកថា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងថ្មីទាំងឡាយដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងនោះក៏ស្របទៅនឹងបទដ្ឋាននៃភាពពាក់ព័ន្ធ ភាពជឿជាក់បាន និងយថាភាព *តាមការវិភាគបឋម* អនុលោមតាមវិធាន ៨៧(៣)។ អង្គជំនុំជម្រះធ្វើសេចក្តីសម្រេចចំពោះការស្នើសុំឱ្យទទួលយកភស្តុតាងថ្មីនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣)។ វិធាន៨៧(៤) ក៏តម្រូវថាគ្រប់ភាគីដែលបានស្នើសុំទទួលយកភ័ស្តុតាងថ្មីត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលសវនាការចាប់ផ្តើមជំនុំជម្រះ ឬមិនអាចរកឃើញ បន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់សមស្របរួចហើយ។ ក៏ប៉ុន្តែនៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកឯកសារជាភ័ស្តុតាងផងដែរ បើទោះបីជាឯកសារនោះមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះក៏ដោយ រួមមានករណីភ័ស្តុតាងនោះជាប់ពាក់ព័ន្ធជាមួយសម្ភារៈ ដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យវាយតម្លៃរួមគ្នាលើប្រភពនៃភ័ស្តុតាងទាំងនោះ...[23]។

10. សហព្រះរាជអាជ្ញាយល់ឃើញថា សម្រាប់ហេតុផលនានាដែលបានពន្យល់ខាងក្រោមនេះ ការវាយតម្លៃ និងការសិក្សាស្តីពីជើងឯក គឺពាក់ព័ន្ធ អាចជឿជាក់បាន មានយថាភូត មិនអាចរកបានមុន

---

[23] **E390/2** សេចក្តីសម្រេចលើសំណើលើកទី១ របស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំកោះហៅសាក្សីបន្ថែមមួយរូប និងទទួលយកកិច្ចសម្ភាសន៍មួយសម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោលនៃសំណុំរឿង ០០២/០២, ៤ ឧសភា ២០១៦, កថាខណ្ឌ ៣។

ពេលជំនុំជម្រះ និងជួយដល់ការស្វែងរកការពិត។ ដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកអនុលោមតាមវិធាន ៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។

11. ការវាយតម្លៃ គឺជារបាយការណ៍កម្រាស់ ៤៦ ទំព័រ ដែលមានគោលបំណងផ្តល់នូវ "ការវាយតម្លៃចុងក្រោយលើគម្រោងអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក"[24] ("គម្រោងជើងឯក") - គម្រោងដូចគ្នាដែលផ្តល់នូវទិន្នន័យសម្រាប់ការសិក្សាអំពីជើងឯក។ យោងតាមការវាយតម្លៃនេះ គឺវាយតម្លៃអំពី "គុណភាព និងផលិតភាពរបស់គម្រោង"[25]។ គម្រោងជើងឯក ដែលបានចាប់ផ្តើមពីខែសីហា ឆ្នាំ២០១៣ មកដល់ខែធ្នូ ឆ្នាំ២០១៥ រួមមានការវិភាគ និងការអភិរក្សលលាដ៍ក្បាលជាច្រើន និង "ឆ្អឹងផ្នែកផ្សេងៗ"[26] ដែលមានរក្សាទុកនៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធជើងឯក ក៏ដូចជាការវិភាគនៃការស្ថាបនាស្តូបគោរពវិញ្ញាណក្ខន្ធថ្មីមួយ ដែលនឹងអាចអភិរក្សវត្ថុដែលរក្សាទុកនៅខាងក្នុងបានល្អជាងនេះ[27]។ ការវាយតម្លៃនេះបញ្ជាក់ថា ឆ្អឹងដែលរក្សាទុកនៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធជើងឯក ត្រូវបានយកមកពីផ្នូរធំៗចំនួន៨៦ ដែលត្រូវបានគាស់ឡើងនៅទីតាំងជើងឯក រវាងឆ្នាំ១៩៨១ និង១៩៨៣[28]។ អដ្ឋិធាតុទាំងនេះដំបូងឡើយត្រូវបានដាក់ទៅក្នុងស្តូបធ្វើអំពីឈើ ហើយត្រូវបានយកមកដាក់នៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធជើងឯកវិញ នៅចុងទសវត្សរ៍ ឆ្នាំ១៩៨០[29]។

12. ការវាយតម្លៃបានពន្យល់ថា គម្រោងជើងឯក "បានសម្រេចជាលទ្ធផល" ៦៤២៦ លលាដ៍ពីស្តូបគោរពវិញ្ញាណក្ខន្ធជើងឯក[30] ក៏ដូចជាអដ្ឋិធាតុគ្រោងឆ្អឹងចំនួន ៦៣,១១២ ផ្សេងទៀតផងដែរ[31]។ វាបង្ហាញថាគម្រោងជើងឯកបានរកឃើញថា ក្នុងចំណោមលលាដ៍ដែលបានពិនិត្យនោះគឺជាលលាដ៍របស់បុរស និងស្ត្រី ក្មេងៗ (រួមទាំងក្មេងអាយុ១៣ឆ្នាំផង[32]) និងមនុស្សពេញវ័យ[33]។ វាក៏បាន

---

[24] ការវាតម្លៃ ត្រង់ ENG 01235380។

[25] Evaluation at ENG 01235381។

[26] បានកំណត់អត្តសញ្ញាណដោយរួមមាន "ឆ្អឹងវែង កង់ឆ្អឹងខ្នង ឆ្អឹងផាល ។ល។" ការវាយតម្លៃត្រង់ ENG 01235382។

[27] ការវាតម្លៃ ត្រង់ ENG 01235425។

[28] ការវាតម្លៃ ត្រង់ ENG 01235398-99.

[29] ការវាតម្លៃ ត្រង់ ENG 01235397

[30] ការវាតម្លៃ ត្រង់ ENG 01235384 (បានកំណត់អត្តសញ្ញាណលលាដ៍ក្បាលចំនួន ៦៤២៦ ដែលត្រូវបានអភិរក្សជាការបានមកពីស្តូបគោរពវិញ្ញាណក្ខន្ត ជើងឯក)។

[31] ការវាតម្លៃ ត្រង់ ENG 01235394។

[32] ការវាតម្លៃ ត្រង់ ENG 01235384 (រូបលេខ១)។

បង្ហាញផងដែរថា គម្រោងជើងឯនេះបានកំណត់អត្តសញ្ញាណអដ្ឋិធាតុជនរងគ្រោះដែលបានមកពីយ៉ាងហោចណាស់ជនរងគ្រោះចំនួន ៧៧០៦ ដាច់ពីគ្នានៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធជើងឯក[34]។

13. ការសិក្សានៅជើងឯក មានស្ទើរតែទាំងស្រុងនៃការវិភាគអដ្ឋិសង្ខលិកយ៉ាងពិស្តារនូវលលាដ៍ក្បាលនីមួយៗ ឬរបស់ដែលនៅសេសសល់របស់មនុស្សផ្សេងៗទៀត ដែលត្រូវបានវិភាគ និងអភិរក្សរួមមាន រូបថតពណ៌នានា ដោយមានមួយទំព័រឧទ្ទិសចំពោះការវាយមុខនីមួយៗដែលបានអភិរក្ស។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថាជាទូទៅ មួយទំព័រនៃការវិភាគបែបនេះសម្រាប់ការទទួលយកទៅដាក់នៅក្នុងសំណុំរឿងថាជាការបញ្ជាក់ព័ត៌មាន ដែលមាននៅក្នុងការសិក្សានៅជើងឯក[35]។

14. ការវាយតម្លៃនេះផ្ទុះបញ្ចាំងអំពីការលើកឡើងដែលថា ការពន្យល់មួយអំពីចំនួនខុសៗគ្នានៃលលាដ៍ដែលត្រូវបានរាយការណ៍នៅពេលផ្សេងៗគ្នានោះគឺថា ដោយសារថាសត្វពាហនៈអាចស៊ីឆ្អឹងមួយចំនួន នៅពេលដែលវាត្រូវបានរក្សាទុកនៅក្នុងស្តូបធ្វើអំពីឈើពីដំបូងនោះ[36] និងបានកត់សម្គាល់ផងដែរថាសូម្បីតែនៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធជើងឯក ដែលអដ្ឋិធាតុត្រូវបានរក្សាទុកចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៨០ មកនោះ "សត្វល្អិត និងសត្វកណ្តុរអាចចេញចូលក្នុងផ្ទៃរស្តូប ហើយក៏អាចបំផ្លាញអដ្ឋិធាតុទៀតផង"[37]។ នេះជាការរួមចំណែកដ៏មានសក្តានុពលដែលនាំឲ្យមានការបាត់បង់ផងដែរ។

15. ការវាយតម្លៃនេះក៏ថ្លែងផងដែរថា ស្តូបគោរពវិញ្ញាណក្ខន្ធជើងឯកមាន "ឧបករណ៍សម្លាប់ជាច្រើនប្រភេទ ដែលត្រូវបានរកឃើញនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍នេះ ជាអាទិ៍មានៈ ពូថៅដៃ ដំបងគល់ឬស្សី ដែកគោ្ករទេះ" ក៏ដូចជា "ខ្សែចំណងល្អសសម្រាប់ចងដៃជនរងគ្រោះ និងខ្នោះជើងរបស់អ្នកទោស"[38]។ រូបថតនៃវត្ថុទាំងនេះ, ឬក៏ស្រដៀងគ្នា, ឧបករណ៍ទំនងជាឃើញមាននៅលើ ២ទំព័រខាងខ្នងភាគច្រើននៃឯកសារសិក្សានៅជើងឯកនិមួយៗ រួមមាន រូបថតដែលបង្ហាញសញ្ញា

---

33 ការវាតម្លៃ ត្រង់ ENG 01235383។

34 ការវាតម្លៃ ត្រង់ 01235383 (ឆ្អឹងដើមដៃចំនួន ៧៧០៦ ត្រូវបានរកឃើញ)។

35 ការសិក្សានៅជើងឯក ដែលបានកំណត់នៅក្នុងឯកសារ E404 ការជូនដំណឹង ភាគទី៣០, ទំព័រ៥៩៨៣។ (ភ្ជាប់ជាឧបសម្ពន្ធ ក)។

36 ការវាតម្លៃ ត្រង់ ENG 01235398-99។

37 ការវាតម្លៃ ត្រង់ ENG 01235421។

38 ការវាតម្លៃ ត្រង់ 01235422។

នៃការប្រើលលាដ៍ និងរូបថតបង្ហាញផ្សេងៗទៀត ("រូបថតនៃការសិក្សានៅជើងឯក")។ ការដាក់ចំណងជើងនៃរូបថតនៃការសិក្សានៅជើងឯក មានជាភាសាខ្មែរ និងអង់គ្លេស នៅក្នុងឯកសារនោះ។ សហព្រះរាជអាជ្ញាស្នើសុំថា រូបថតស្ដីពីការសិក្សានៅជើងឯក ត្រូវទទួលយកធ្វើជាភស្តុតាង[39]។

16. ការវាយតម្លៃនេះក៏បានកត់សម្គាល់ផងដែរថា ការសិក្សាឆ្នាំ២០០៤ ដែលត្រូវបានធ្វើឡើងដោយ Joint POW/MIA Accounting Command's Central Identification Laboratory (JPAC-CIL) រួមជាមួយនឹងក្រុមមួយមកពី "Harris County Medical Examiner's Office" បានពិនិត្យលលាដ៍ចំនួន៨៥ ដែលបានជ្រើសរើសដោយព្រាវនៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធជើងឯក។ យោងតាមការវាយតម្លៃនេះ "ក្រុមអ្នកស្រាវជ្រាវបានរកឃើញនូវភស្តុតាងជាច្រើននៃស្លាកស្នាម ដែលបណ្ដាលមកពីអំពើហិង្សាដូចគ្នានឹងការនិយាយរឿងប្រាប់របស់សាក្សីនានា ដូចជា ហ៊ឹម ហុយ ជាដើម មេពេជ្ឈឃាដដែលបានសារភាពនៅវាលពិឃាតជើងឯក)។ ការប៉ះទង្គិចធ្ងន់ធ្ងរដោយឧបករណ៍ទាល ស្លាកស្នាមនៃជនរងគ្រោះទាំងអស់ គឺបណ្ដាលមកពីការបាញ់កាំភ្លើង ចាក់នឹងកាំបិត អារបំពង់ក យកថង់ខ្ទប់មុខ ដើម្បីសម្លាប់ដែលទាំងនេះធ្វើឡើងដោយវាយនឹងខ្នងពូថៅ ឈើវែង ដំបងឫស្សី ពូថៅ ដែកគ្នៀរទេះ និងប៉ែលជាដើម"[40]។

17. ឯកសារសិក្សានៅជើងឯកនិមួយៗ មានផងដែរតារាងមួយដែលសង្ខេបការរកឃើញនូវអដ្ឋិធាតុមនុស្សដែលបានវិភាគនៅក្នុងឯកសារសិក្សានោះ ("តារាងសង្ខេបនៃឯកសារសិក្សានៅជើងឯក")។ តារាងទាំងនោះរួមមានព័ត៌មានពាក់ព័ន្ធនឹងចំនួនស្លាកស្នាមលើអដ្ឋិធាតុដែលបានបំបែកដោយប្រភេទឧបករណ៍ផ្សេងៗពីគ្នា ហើយអាយុ និងភេទរបស់ជនរងគ្រោះដែលគេអាចកំណត់បាន។ សហព្រះរាជអាជ្ញាស្នើថា តារាងទាំង៣២នេះត្រូវតែទទួលជាភស្តុតាង[41]។

18. ការវាយតម្លៃនេះខ្លួនឯងផ្ទាល់កំណត់អំពីសារសំខាន់របស់គម្រោងជើងឯក (ទិន្នន័យដែលបានផ្ទុះបញ្ចាំងនៅក្នុងការវាយតម្លៃ និងការសិក្សាស្ដីពីជើងឯក) បាននិយាយថាវា "មានសារសំខាន់ណាស់ដោយហេតុផលថា វាជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រនៃអដ្ឋិធាតុ ដែលយកពីរណ្ដៅសាកសព

[39] ការសិក្សានៅជើងឯក ដែលបានកំណត់នៅក្នុងឯកសារ E404 ការជូនដំណឹង។ ភាគទី៣២, គ្មានលេខទំព័រ។ (ភ្ជាប់ជាឧបសម្ព័ន្ធ ខ)។

[40] ការវាតម្លៃ ត្រង់ ENG 01235400។

[41] ការសិក្សានៅជើងឯក ដែលបានកំណត់នៅក្នុងឯកសារ E404។ ភាគទី១-៣២, តារាងសង្ខេប គ្មានលេខទំព័រ។ (ភ្ជាប់ជាឧបសម្ព័ន្ធ គ រួម)។

នៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកមកវិភាគ ហើយមានគម្រោងជាក់លាក់មួយសម្រាប់ប្រមូលព័ត៌មានទាំងអស់ពីអដ្ឋិធាតុដែលមាននៅលើដី និងព័ត៌មានអំពីឆ្អឹងទាំងអស់ដែលមាននៅក្នុងស្តូបគោរពវិញ្ញាណក្ខន្ធ”[42]។

19. ការវាយតម្លៃនេះ និងទំព័រនៃការសិក្សាស្តីពីជើងឯក គឺពាក់ព័ន្ធទៅនឹងការចោទប្រកាន់នានានៅក្នុងសំណុំរឿង០០២/០២ ដោយសារវាទាក់ទងនឹងការសម្លាប់នៅជើងឯក និងទីតាំងកប់សាកសពដែលបង្កើតបានជាផ្នែកនៃការចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរ ស-២១ ក្នុងសំណុំរឿង០០២/០២[43]។ ការវាយតម្លៃនេះ និងទំព័រនៃការសិក្សាស្តីពីជើងឯក ក៏ពាក់ព័ន្ធទៅនឹងភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងរួចហើយដែរ។ វាពាក់ព័ន្ធផ្ទាល់ទៅនឹងអត្ថបទ ដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះនេះរួចហើយ។ អង្គជំនុំជម្រះផ្តល់នូវភស្តុតាងជាក់លាក់ដែលមាននៅក្នុងអត្ថបទថា មានភាពជឿជាក់ជាង ដោយបានរៀបរាប់ និងបង្ហាញអំពីនីតិវិធីហ្មត់ចត់ដែលសេចក្តីសន្និដ្ឋាននានាត្រូវបានធ្វើឡើង និងនីតិវិធីនោះស្របទៅនឹងភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងការសម្លាប់នៅជើងឯក។

20. ឧទាហរណ៍ អត្ថបទនោះថ្លែងថា គម្រោងជើងឯកបានសន្និដ្ឋានថា វិធីសាស្ត្រនានានៃការសម្លាប់រួមមាន ប្រភេទជាច្រើននៃការប៉ះទង្គិចធ្ងន់ធ្ងរដោយឧបករណ៍ទាល (blunt force trauma) នៅត្រង់ក្បាល និងការអារករបស់ជនរងគ្រោះ។ ស្ថានភាពនេះស្របគ្នាទៅនឹងការអនុវត្តនៃការសម្លាប់ដូចបានបង្ហាញឡើងតាមរយៈរូបភាពនៃការសិក្សាស្តីពីជើងឯក ព្រមទាំង សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះក្នុងសំណុំរឿង០០២/០២។ សាក្សី 2-TCW-865 ដែលជាសាក្សីឃើញផ្ទាល់ភ្នែកនូវការសម្លាប់នៅជើងឯក បាននិយាយនៅចំពោះមុខអង្គជំនុំជម្រះនេះ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ថា៖ “ការសម្លាប់មនុស្សគឺគេធ្វើតែអីចឹង” នៅជើងឯកគឺថា “[គេ]ប្រើទុយោដើម្បីវាយចំកញ្ចឹងក នៅពេលដែលអ្នកទោសដួល គេដោះខ្នោះចេញ បន្ទាប់មកគេយកកាំបិតទៅបង្ហើយការសម្លាប់របស់ពួកគេ...”[44]។ គាត់ក៏បានបញ្ជាក់ផងដែរអំពីសច្ចភាពនៃចម្លើយរបស់

---

42 ការវាយតម្លៃ ត្រង់ ENG 01235394។

43 **E301/9/1.1** បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះ សំណុំរឿងលេខ ០០២/០២, ៤ មេសា ២០១៤, កថាខណ្ឌ ៣(vi); **D427** ដីកាដំណោះស្រាយ សំណុំរឿង០០២, ១៥ កញ្ញា ២០១០, កថាខណ្ឌ ៤១៥ (“មន្ទីរសន្តិសុខ ស-២១ (ស-២១) រួមមានមន្ទីរឃុំឃាំងមួយ នៅក្នុងទីក្រុងភ្នំពេញ និងកន្លែងសម្លាប់មនុស្សមួយនៅ (ជើងឯក) ដែលមានចម្ងាយ១៥គីឡូម៉ែត នៅភាគនិរតីនៃទីក្រុងភ្នំពេញក្នុងខេត្តកណ្តាល”)។

44 សេចក្តីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, នៅម៉ោង 15.39.44។

សាក្សី ហ៊ឹម ហ៊ុយ ដែលបាននិយាយថានៅពេលដែលជនរងគ្រោះ "ទៅដល់រណ្ដៅនោះ យើងប្រាប់អ្នកទោសឲ្យអង្គុយ ហើយបន្ទាប់មកគេវ៉ៃអ្នកទោសពីខាងក្រោយដោយប្រើដែកភ្លៅរទេះ ហើយគេអារក ស្រាយចំណងដៃ បន្ទាប់មកគេធាក់ទម្លាក់ទៅក្នុងរណ្ដៅ..."[45]។ ស្រដៀងគ្នានេះដែរ នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ សាក្សី ហ៊ឹម ហ៊ុយ បានរៀបរាប់ប្រាប់អង្គជំនុំជម្រះនេះអំពីការដែលត្រូវបានណែនាំថា "អីចឹងវ៉ៃហើយសន្លប់ សន្លប់ហើយអារក"[46]។ បន្ថែមលើនេះ ការពិពណ៌នានៅក្នុងការវាយតម្លៃនៃសិក្សា JPAC-CIL ឆ្នាំ២០០៤ គឺវាស៊ីចង្វាក់គ្នាទៅនឹងភ័ស្តុតាងនេះទាក់ទងនឹងលក្ខណៈនៃការសម្លាប់ និងឧបករណ៍ដូចបានបង្ហាញតាមរយៈរូបថតនៅក្នុងការសិក្សាស្ដីពីជើងឯក និងកាលបរិច្ឆេទនៅក្នុងតារាងសង្ខេបនៃការសិក្សាស្ដីពីជើងឯក។ ជារួម ព័ត៌មាននៅក្នុងការវាយតម្លៃ រូបថតនៃសិក្សាស្ដីពីជើងឯក និងតារាងសង្ខេបនៃការសិក្សាស្ដីពីជើងឯក ដែលពាក់ព័ន្ធនឹងអត្តសញ្ញាណ និងរបៀបនៃការស្លាប់របស់ជនរងគ្រោះមួយចំនួននៅជើងឯក មានទំនាក់ទំនងទៅនឹងភ័ស្តុតាងផ្សេងទៀតទាំងអស់ក្នុងសំណុំរឿង ដែលទាក់ទងនឹងការសម្លាប់ និងការកប់សាកសពនៅជើងឯក។

21. ការវាយតម្លៃ និងការសិក្សាស្ដីពីជើងឯក គឺអាចជឿជាក់បាន។ ការវាយតម្លៃត្រូវបានធ្វើឡើងដោយបណ្ឌិត Nancy Beavan ដែលយោងទៅតាមគុណវុឌ្ឍិរបស់លោកស្រីដែលបានរាយការណ៍នៅក្នុងរបាយការណ៍ ជាបណ្ឌិតខាងការវិភាគ Isotopic - a PhD in Isotopic Analysis, ជាបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រនៅក្នុងការវិភាគ និងជាបរិញ្ញាប័ត្រផ្នែករូប-ភូមិសាស្ត្រ[47]។ គាត់មានបទពិសោធន៍វិជ្ជាជីវៈជាច្រើន ផងដែរ រួមមាន ជាអ្នកចាត់ចែងនៅមន្ទីរពិសោធន៍ Rafter Radiocarbon Laboratory ចំនួន១៥ឆ្នាំ នៅវិទ្យាស្ថានភូគុព្ភសាស្ត្រ និងវិទ្យាសាស្ត្រនុយក្លេអ៊ែរ ប្រទេសនូវែលហ្សេឡង់ដ៍, មានទំនាក់ទំនងជាមួយនឹងទិនានុប្បវត្តិនៃបណ្ឌិតសភាដែលពាក់ព័ន្ធ, ហើយមានបទពិសោធន៍ពីមុននៅក្នុង ការពិនិត្យសារឡើងវិញលើគម្រោង[48]។ ការវិភាគរបស់គាត់គឺមានមូលដ្ឋាននៅលើការស្រាវជ្រាវរបស់គាត់ផ្ទាល់ និងនៅលើទិន្នន័យដែលបានបង្កើតឡើងដោយក្រុមការងារដែលបានដឹកនាំគម្រោងជើងឯក[49]។ ទិន្នន័យដែលបានបង្កើតឡើងដោយគម្រោង

[45] សេចក្ដីព្រាងប្រតិចារឹក, ២១ មេសា ២០១៦, នៅម៉ោង 15.53.01-15.45.03។

[46] សេចក្ដីព្រាងប្រតិចារឹក, ៤ ឧសភា ២០១៦, នៅម៉ោង 11.07.32។

[47] ការវាយតម្លៃ ត្រង់ ENG 01235395។

[48] ការវាយតម្លៃ ត្រង់ ENG 01235395។

[49] ការវាយតម្លៃ ត្រង់ ENG 01235396។

ជើងឯក ដែលមាននៅក្នុងការសិក្សាស្តីពីជើងឯក ហើយដែលការវាយតម្លៃបានធ្វើការសង្ខេបនោះ គឺអាចជឿជាក់បានដោយមកពីសេចក្តីសន្និដ្ឋានរបស់បណ្ឌិត Beaven ដែលថាគម្រោងនោះគឺជា "កម្មវិធីមួយដែលមានប្រសិទ្ធភាពបំផុត ដែលទទួលបានជោគជ័យនៅគ្រប់ទិសដៅ និងធាតុចេញរបស់វា"[50] និងក៏ដោយសារនៃគុណវុឌ្ឍិរបស់បុគ្គលនានាដែលបានដឹកនាំធ្វើគម្រោងជើងឯកផ្ទាល់។ ការវាយតម្លៃបានពន្យល់ថា លោកនាយកកម្មវិធីនៃគម្រោងជើងឯក, វឿន វុឌ្ឍី, មានបរិញ្ញាប័ត្រពីមហាវិទ្យាល័យបុរាណវត្ថុវិទ្យា និងជាបរិញ្ញាប័ត្រជាន់ខ្ពស់ ក្នុងផ្នែកស្នូនសត្វបុរាណវត្ថុវិទ្យា ហើយបានចូលរួមចំណែកនៅក្នុងវគ្គសិក្សាផ្សេងៗទៀត នៅក្នុងវិធីសាស្ត្រអភិរក្សឆ្អឹង[51]។ ជាការបន្ថែមទៅនឹងបទពិសោធ វិជ្ជាវៈផ្សេងៗទៀត ចាប់តាំងពីឆ្នាំ២០១៣ លោក វុឌ្ឍី ធ្លាប់ធ្វើជាប្រធានមន្ទីរពិសោធខាងអភិរក្សឆ្អឹងមនុស្សនៅមជ្ឈមណ្ឌលប្រល័យពូជសាស្ត្រជើងឯក ហើយចាប់តាំងពីឆ្នាំ២០១៤ គាត់ធ្វើជានាយកផ្នែកបុរាណវត្ថុវិទ្យា និងនាយកដ្ឋានបុរេប្រវត្តិសាស្ត្រ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ[52]។

22. យថាភាពនៃការវាយតម្លៃនេះ និងការសិក្សាស្តីពីជើងឯក គឺត្រូវបានបញ្ជាក់បន្ថែមដោយការប្រាស្រ័យទាក់ទងរបស់អង្គជំនុំ ជម្រះសាលាដំបូង ជាមួយនឹងលោក វឿន វុឌ្ឍី, លោកស្រី Julie Fleischman, និងលោកស្រី រស់ សុភារ៉ាវី[53]។

23. វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ចែងថា ភាគីដែលស្នើសុំដាក់ជូននូវភស្តុតាងថ្មីត្រូវធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំពុំអាចរកបានទេនៅមុនពេលចាប់ផ្តើមបើកការជំនុំជម្រះ។ អង្គជំនុំជម្រះបានសម្រេចថា ចំពោះសំណុំរឿង០០២/០២ ការចាប់ផ្តើមបើកសវនាការគឺនៅ ខែមិថុនា ឆ្នាំ២០១១[54]។ ការវាយតម្លៃត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១៥[55]។ យោងទៅតាម

---

[50] ការវាយតម្លៃ ត្រង់ ENG 01235425។

[51] ការវាយតម្លៃ ត្រង់ ENG 01235402។

[52] ការវាយតម្លៃ ត្រង់ ENG 01235402។

[53] **E404** ការជូនដំណឹង, ត្រង់កថាខណ្ឌ ២។

[54] **E307/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺ អំពីការអនុវត្តវិធាន៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែល បានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)", ១១ មិថុនា ២០១៤។ **E307/1/2** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើសំណើសុំរួមឲ្យសម្រេច*សាជាថ្មីឡើងវិញ* លើការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង", ២១ តុលា ២០១៤, កថាខណ្ឌ១០។

[55] ការវាយតម្លៃ ត្រង់ ENG 01235379។

ព័ត៌មានដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូង វាត្រូវអាចរកបាននៅបណ្ណាល័យ អវតក ជាភាសាអង់គ្លេស និងជាភាសាខ្មែរចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៦។ វាត្រូវបានដាក់នៅក្នុងឃ្លាំងសម្ភារៈរួម នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦។ ដូច្នេះ ការវាយតម្លៃពុំអាចរកបានទេនៅមុនពេលចាប់ផ្តើមសវនាការនៅក្នុងសំណុំរឿង០០២/០២។ ទោះបីជាការវាយតម្លៃទំនងជាអាចរកបាននៅក្នុងបណ្ណាល័យ អវតក ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៦ ក៏ដោយ ក៏វាទំនងជាទាំងអង្គជំនុំជម្រះសាលាដំបូង ទាំងភាគីនានា មិនបានដឹងពីអត្ថិភាពរបស់វា ឬក៏ពីទីកន្លែងរបស់វាថានៅទីនោះទេ។

24. ការសិក្សាអំពីជើងឯកចំនួន៣២ភាគ ត្រូវបានបោះពុម្ពផ្សាយនៅចន្លោះឆ្នាំ២០១៣ និង២០១៥។ យោងតាមព័ត៌មានដែលអង្គជំនុំជម្រះសាលាដំបូងទទួលបាន ១២ភាគ ដំបូង នៃការសិក្សាអំពីជើងឯកត្រូវបានបញ្ជូនមកកាន់ អ.វ.ត.ក "ក្នុងឆ្នាំ២០១៤" ដែល ១១ភាគ ក្នុងចំណោមនោះ អាចរកបាននៅបណ្ណាល័យជាភាសាខ្មែរតែប៉ុណ្ណោះតាំងពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥មកម្លេះ ហើយភាគដែលនៅសល់ដែលមានតែជាភាសាខ្មែរនោះ មាននៅក្នុងបណ្ណាល័យក្នុងពេលណាមួយក្រោយថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦។ ហេតុដូច្នេះ ការសិក្សាអំពីជើងឯកមិនអាចរកបានឡើយ មុនពេលចាប់ផ្តើមការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២។ ទោះបីជាទំនងជាអាចរកបាននៅបណ្ណាល័យ អ.វ.ត.ក ចាប់តាំងពីពេលណាមួយក្នុងឆ្នាំ២០១៤ក៏ដោយ ក៏វាហាក់ដូចជាថា ទាំងអង្គជំនុំជម្រះសាលាដំបូង ទាំងភាគីនានា មិនបានដឹងអំពីវត្តមានរបស់វា ឬក៏ទីតាំងរបស់វានៅទីនោះឡើយ។

25. សហព្រះរាជអាជ្ញា មិនស្វែងរកឲ្យទទួលយកភាគដែលនៅសល់ក្នុងចំណោមភាគទាំង៣២ នៃការសិក្សាអំពីជើងឯក (ជាជាងអត្ថបទស្តីពីការសិក្សានៅជើងឯក) នៅពេលនោះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ហើយថា ភាគច្រើននៃការសិក្សាអំពីជើងឯក បច្ចុប្បន្ន គឺអាចរកបានតែភាសាខ្មែរប៉ុណ្ណោះ[56]។ សហព្រះរាជអាជ្ញាមិនមានការជឿជាក់ថា វាចាំបាច់ក្នុងការមានការវិភាគពិស្តារនៃអដ្ឋិធាតុនីមួយៗដែលបានវិភាគនៅក្នុងការសិក្សានៅជើងឯក ដែលបានដាក់ទៅក្នុងសំណុំរឿង មានមួយភាសានៅពេលនេះ នៅក្នុងសំណុំរឿង០០២/០២នោះឡើយ ជាពិសេសពីព្រោះភាគជាច្រើននៃការរកឃើញសំខាន់ៗនៃការសិក្សាអំពីជើងឯក ត្រូវបានសង្ខេបនៅក្នុងការវាយតម្លៃ ការសិក្សានៅជើងឯក និងអត្ថបទនោះរួចហើយ។ សហព្រះរាជអាជ្ញាយល់ឃើញថា ប្រសិនមានភាគីណាមួយមានបំណងជំទាស់ទៅនឹងការការដាក់បង្ហាញនូវការវាយតម្លៃអត្ថបទ ឬ

56 **E404** ការជូនដំណឹង, គ្រង់កថាខណ្ឌ ៥។

ទំព័រនៃការសិក្សាអំពីជើងឯកដែលពាក់ព័ន្ធនឹងគម្រោងជើងឯកនោះ ផ្នែកពាក់ព័ន្ធបន្ថែមទៀតណាមួយ ឬផ្នែកនៃការសិក្សាអំពីជើងឯកនោះ អាចនឹងត្រូវបានស្នើសុំឲ្យទទួលយកនៅពេលនោះ។

## III. **ដំណោះស្រាយដែលស្នើឡើង**

26. ដូច្នេះ សហព្រះរាជអាជ្ញាសូមគោរពស្នើសុំថា អង្គជំនុំជម្រះសាលាដំបូងទទួលយកការវាយតម្លៃរូបថតនៃការសិក្សាស្តីពីជើងឯក និងតារាងសង្ខេបនៃការសិក្សាស្តីពីជើងឯក ជាភស្តុតាងនៅក្នុងសំណុំរឿង០០២ ដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |